## លេខាធិការដ្ឋាន គ.ជ.អ.ប

## ការពិពណ៌នាការងារ (Job Description - JD)

| | |
|---|---|
| **កម្មវិធីជាតិ** | កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ផែនការអនុវត្តរយៈពេលបីឆ្នាំដំណាក់កាលទី២ (ផ.អ៣ ២០១៥-២០១៧) |
| **មុខតំណែង** | បុគ្គលិកព័ត៌មានវិទ្យាថ្នាក់រាជធានី ខេត្ត (PITO) |
| **ទីកន្លែងបំពេញការងារ** | រដ្ឋបាលរាជធានី ខេត្ត |
| **រយៈពេល** | មួយឆ្នាំ (អាចបន្ត) |

### ១. សាវតារ

ផែនការអនុវត្តដំណាក់កាលទី១ (២០១១-២០១៤) ផ្តោតការយកចិត្តទុកដាក់ទៅលើការពង្រឹង និងការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលក្រុង ស្រុក ឱ្យក្លាយជាស្ថាប័នអភិបាលកិច្ចមូលដ្ឋាន និងអភិវឌ្ឍមូលដ្ឋានយ៉ាងពិតប្រាកដ។ មូលដ្ឋានគ្រឹះសំខាន់ៗ ដូចជារចនាសម្ព័ន្ធ នីតិវិធី ប្រព័ន្ធ និងឧបករណ៍ជាច្រើនសម្រាប់ការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំឡើងវិញ និងបានផ្តល់ជាបង្អែកយ៉ាងរឹងមាំសម្រាប់ការបោះជំហានឆ្ពោះទៅមុខ។ ទាំងនេះបណ្តាលឲ្យផអ៣ទី១ ក្លាយជាកម្លាំងចលករមួយដ៏សំខាន់ សម្រាប់ការងារកំណែទម្រង់ និងជាសនិទានកម្មដ៏សំខាន់ ដែលនាំឲ្យរាជរដ្ឋាភិបាល តាមរយៈកិច្ចប្រជុំលើកទី១០ របស់ គ.ជ.អ.ប កាលពីខែធ្នូ ឆ្នាំ២០១៤ បានសម្រេចបន្តអនុវត្តដំណាក់កាលទី២ (ផអ៣ទី២) ដែលចាប់ផ្តើមពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៧។

ចក្ខុវិស័យនៃផអ៣ទី២នេះគឺ "រដ្ឋបាលថ្នាក់ក្រោមជាតិផ្តល់សេវា និងអភិវឌ្ឍមូលដ្ឋានបានកាន់តែច្រើន កាន់តែល្អប្រសើរ កាន់តែមានលក្ខណៈឆ្លើយតបចំពោះសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋរបស់ខ្លួន"។ ផអ៣ទី២បន្តផ្តោតការយកចិត្តទុកដាក់ជាសំខាន់ទៅលើរដ្ឋបាលក្រុង ស្រុក ប៉ុន្តែក៏មានការពាក់ព័ន្ធជាមួយនឹងថ្នាក់រដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងៗទៀតផងដែរ។ ទាក់ទងជាមួយភ្នាក់ងារអនុវត្តនៅថ្នាក់ជាតិ ក្នុងក្របខណ្ឌផអ៣ទី២ នឹងមិនអនុវត្តដោយអនុកម្មវិធីទៀតទេ។ ភ្នាក់ងារអនុវត្តនៅថ្នាក់ជាតិ គឺជាក្រសួងស្ថាប័នទាំងឡាយណាដែលមានការពាក់ព័ន្ធជាមួយការងារកំណែទម្រង់ ជាពិសេសការផ្ទេរមុខងារនិងធនធានក្នុងការផ្តល់សេវានិងការអភិវឌ្ឍមូលដ្ឋាន។ សមិទ្ធផលសំខាន់ៗនៃការផ្ទេរមុខងារគឺរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាព ក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងការទទួលបាននូវសេវា ហើយការផ្តល់សេវានឹងត្រូវអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានលក្ខណៈសមស្រប និងនៅកៀកបំផុតនឹងប្រជាពលរដ្ឋ។ ការផ្ទេរមុខងារជាបឋមមានការផ្ទេរមុខងារជាក់លាក់និងសមស្របមួយចំនួនពីក្រសួងទៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងការផ្ទេរមុខងារនៃសេវាទីប្រជុំជនពីរដ្ឋបាលខេត្ត ទៅរដ្ឋបាលក្រុងស្រុក។

ចក្ខុវិស័យសម្រាប់ធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺការប្រើប្រាស់ធនធានទាំងអស់ដែលមានរួមទាំងមន្ត្រីរាជការស៊ីវិល បុគ្គលិកកិច្ចសន្យា ទាំងផ្នែកឯកជន និងអង្គការសង្គមស៊ីវិល។ ការបង្កើតមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សនៅរាជធានី ខេត្ត គឺជាយន្តការថ្មីមួយទៀតនៃផអ៣ទី២ ដែលសង្ឃឹមថានឹងធានាបាននូវការរៀបចំវិធីសាស្ត្រនៃការអភិវឌ្ឍសមត្ថភាពដែលមានលក្ខណៈឆ្លើយតប និងប្រកបដោយការផ្តួចផ្តើម សំដៅសម្រេចបានដោយជោគជ័យក្នុងការអភិវឌ្ឍសមត្ថភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

ការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីរាជការនឹងត្រូវបន្តពង្រឹងតាមរយៈទីប្រឹក្សានៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ។ ជាលទ្ធផលនៃការអភិវឌ្ឍសមត្ថភាព គេសង្ឃឹមថាជំនួយបច្ចេកទេសនឹងត្រូវបានបន្ថយជាបណ្តើរៗ ឬជំនួយបច្ចេកទេសទាំងនេះត្រូវបានបង្វែរពីថ្នាក់រាជធានី ខេត្ត ទៅថ្នាក់ក្រុង ស្រុក ជាពិសេសគឺត្រូវធ្វើការផ្លាស់ប្តូរនូវទម្លាប់និងឥរិយាបថនៃការប្រើប្រាស់ជំនួយបច្ចេកទេស ដែលទីប្រឹក្សាតែងតែបំពេញការងារជំនួសមន្ត្រីរាជការ ទៅជាបែបផែនដែលទីប្រឹក្សាត្រូវផ្តោតតែលើការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីរាជការ។ ដូចនេះ បុគ្គលិកកិច្ចសន្យា ទីប្រឹក្សាដែលស្ថិតនៅក្នុងក្របខណ្ឌផអ៣ទី២ ចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើការសម្របសម្រួល និងការផ្តល់កិច្ចអន្តរាគមន៍ផ្នែកអភិវឌ្ឍន៍សមត្ថភាពឱ្យបានច្រើនជាងមុន ប្រកបដោយគុណភាពនិងភាពសក្តិសិទ្ធជាជាងទម្លាប់នៃការធ្វើជំនួស។ បុគ្គលិកកិច្ចសន្យា និងទីប្រឹក្សាត្រូវផ្ទេរចំណេះដឹងដល់ដៃគូរបស់ខ្លួនយ៉ាងតិចក្នុង២ដំណាក់កាលៈ ដំណាក់កាលទី១ គឺជាការបង្រៀនផងនិងជួយធ្វើការផងដូចជា ជាបឋមត្រូវតម្រង់ទិសឲ្យយល់អំពីតួនាទីនិងភារកិច្ចរបស់ខ្លួន និងស្ថាប័នរបស់ខ្លួន របៀបបំពេញការងារ ការរៀបចំផែនការការងារ ការចាត់អាទិភាពការងារ ការនាំឲ្យចូលរួមផ្ទាល់ក្នុងសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងកិច្ចប្រជុំតាមមូលដ្ឋានជាដើម។ ដំណាក់កាលទី២ គឺជាការពង្រឹងបន្ថែម និងការកែតម្រូវតាមរយៈការត្រួតពិនិត្យលើការបំពេញការងារ ដោយផ្អែកលើគុណភាព ភាពទាន់ពេល និងភាពមានទំនុកចិត្តក្នុងការបំពេញការងារ។ នេះជាលក្ខណៈវិនិច្ឆ័យចម្បងនៃការវាយតម្លៃការបំពេញការងាររបស់បុគ្គលិកកិច្ចសន្យានិងទីប្រឹក្សាកម្មវិធី។

ដើម្បីជំនះបាននូវបញ្ហាប្រឈមគួរឲ្យព្រួយបារម្ភដែលអធិប្បាយខាងលើ ទីប្រឹក្សានិងបុគ្គលិកកិច្ចសន្យា នៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនានាដែលក្នុងនោះរួមទាំងបុគ្គលិកព័ត៌មានវិទ្យាថ្នាក់រាជធានី ខេត្ត នឹងត្រូវជ្រើសរើស និងតែងតាំងឲ្យទៅបម្រើការងារយ៉ាងជិតស្និទ្ធជាមួយក្រុមប្រឹក្សា គណៈអភិបាល និងទីចាត់ការនានារបស់រដ្ឋបាលរាជធានី ខេត្ត ដើម្បីអភិវឌ្ឍសមត្ថភាពក្នុងការបំពេញអណត្តិរបស់ខ្លួន។

លទ្ធផលនៃការបំពេញការងាររបស់បុគ្គលិកព័ត៌មានវិទ្យាថ្នាក់រាជធានី ខេត្ត នឹងត្រូវបានវិនិច្ឆ័យដោយផ្អែកលើលទ្ធផល និងកម្រិតនៃការផ្ទេរចំណេះដឹងនិងជំនាញរបស់បុគ្គលិកនោះទៅឱ្យមន្ត្រីរាជការ និងបុគ្គលិកដែលជាដៃគូរបស់ខ្លួន។

## ២. តួនាទី និងភារកិច្ច

### ២.១. តួនាទី និងភារកិច្ចទូទៅ

បុគ្គលិកព័ត៌មានវិទ្យាថ្នាក់រាជធានី ខេត្តមានភារៈកិច្ចធានាឱ្យរាល់គ្រប់ប្រព័ន្ធទំនាក់ទំនង និងព័ត៌មានវិទ្យានៅថ្នាក់រាជធានី ខេត្តមានដំណើរការល្អហើយត្រូវធ្វើបច្ចុប្បន្នភាព និងថែរក្សាដំណើរការជាប្រចាំ។

### ២.២. ភារកិច្ចជាក់លាក់

ភារកិច្ចសំខាន់ៗរបស់បុគ្គលិកព័ត៌មានវិទ្យាថ្នាក់រាជធានី ខេត្តមានដូចខាងក្រោមៈ

- គ្រប់គ្រងប្រព័ន្ធកុំព្យូទ័រ និងបណ្តាញទំនាក់ទំនងនៅក្នុងសាលារាជធានី ខេត្តបញ្ចូល និងថែទាំប្រព័ន្ធទិន្នន័យ និងប្រព័ន្ធអ៊ីម៉ែល/គេហទំព័រ ។
- ជួយដល់សាលារាជធានី ខេត្តក្នុងការជួសជុលថែទាំប្រព័ន្ធកុំព្យូទ័រ និងដោះស្រាយបញ្ហានានាទាក់ទងទៅនឹងផ្នែកព័ត៌មានវិទ្យា រួមទាំងការថែទាំជាប្រចាំ ការបញ្ចូលនិងថែទាំកម្មវិធីកម្ចាត់មេរោគកុំព្យូទ័រ និងកម្មវិធីកុំព្យូទ័រ។
- ផ្តល់ការសម្របសម្រួលដល់ទីចាត់ការពាក់ព័ន្ធនានា ទាក់ទងទៅនឹងការគ្រប់គ្រងប្រព័ន្ធទិន្នន័យ ។

ចូលរួមជួយប្រមូលទិន្នន័យនានា ពាក់ព័ន្ធនឹងការកសាងប្រព័ន្ធគ្រប់គ្រងព័ត៌មាន (MIS)។

- សហការ និងគាំទ្របច្ចេកទេសដល់មន្ត្រីទទួលបន្ទុកប្រព័ន្ធទិន្នន័យរបស់មន្ទីរវិស័យនានា និងទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់រាជធានី ខេត្ត ដើម្បីធានាថាការបញ្ចូលទិន្នន័យក្នុងប្រព័ន្ធទិន្នន័យរបស់គ.ជ.អ.ប (NAD, PID, CDB, SPD, DIS... ) ទាន់ពេលវេលា និងត្រឹមត្រូវ ព្រមទាំងរៀបចំរបាយការណ៍។
- សហការជិតស្និទ្ធជាមួយទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់រាជធានី ខេត្តដើម្បីធានាគុណភាពក្នុងការបញ្ចូលទិន្នន័យទាក់ទងនឹងការត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងកត់ត្រានូវព័ត៌មានពាក់ព័ន្ធពីថ្នាក់ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត។
- គាំទ្រដល់ដំណើរការរៀបចំប្រព័ន្ធទិន្នន័យនៃកម្មវិធីគណនេយ្យភាពសង្គម និងគាំទ្រដល់ដំណើរការនៃការបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធទិន្នន័យនេះ។
- បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពបុគ្គលិករដ្ឋបាលឯកភាព និងជំនួយការរដ្ឋបាល និងព័ត៌មានវិទ្យាថ្នាក់ក្រុង ស្រុក ខណ្ឌតាមរយៈការបង្ហាត់បង្ហាញទាក់ទងទៅនឹងជំនាញគ្រប់គ្រងប្រព័ន្ធទិន្នន័យ និងកម្មវិធីព័ត៌មានវិទ្យាផ្សេងៗ។
- គាំទ្រជាប្រចាំដល់ការពង្រឹង និងការអនុវត្តវិស័យព័ត៌មានវិទ្យានៅថ្នាក់ក្រុង ស្រុក ខណ្ឌ
- សហការជាមួយការិយាល័យទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាននៃលេខាធិការដ្ឋានគ.ជ.អ.ប ក្នុងការផ្តល់ព័ត៌មានអំពីព្រឹត្តិការណ៍ផ្សេងៗដែលកើតឡើងក្នុងខេត្តពាក់ព័ន្ធ ផអ៣ទី២
- សម្របសម្រួល និងចូលរួមនៅក្នុងការគាំទ្របច្ចេកទេស និងវាយតម្លៃការបំពេញការងាររបស់ជំនួយការរដ្ឋបាល និងព័ត៌មានវិទ្យាថ្នាក់ក្រុងស្រុក ខណ្ឌ។
- រៀបចំផែនការ និងរបាយការណ៍ការងារប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ និងដាក់ជូនទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់រាជធានី ខេត្ត និងនាយករដ្ឋបាលសាលារាជធានី ខេត្ត។
- បុគ្គលិកព័ត៌មានវិទ្យាថ្នាក់រាជធានី ខេត្តទទួលខុសត្រូវចូលរួមក្នុងការបញ្ជ្រាបយេនឌ័រការលើកកម្ពស់យេនឌ័រតាមរយៈអនុវត្តជាក់ស្តែងនៅក្នុងកិច្ចការនានា ដែលពាក់ព័ន្ធការទទួលខុសត្រូវរបស់ខ្លួន។
- បំពេញការងារផ្សេងៗទៀតតាមការស្នើសុំរបស់នាយករដ្ឋបាល នាយកទីចាត់ការសាលារាជធានី ខេត្ត ឬទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់រាជធានី ខេត្ត។

ក្រៅពីភារកិច្ច និងការទទួលខុសត្រូវខាងលើ បុគ្គលិកព័ត៌មានវិទ្យាថ្នាក់រាជធានី ខេត្ត ត្រូវបានបន្ថែមតួនាទី ភារកិច្ចជាក់លាក់មួយផ្សេងទៀត ដើម្បីជួយសម្របសម្រួល និងគាំទ្រដល់ក្រុមការងារបច្ចេកទេសរបស់មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត ដែលរួមមាន៖

- រក្សាទំនាក់ទំនងជិតស្និទជាមួយការិយាល័យព័ត៌មានវិទ្យានៃអង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មានរបស់លេខាធិការដ្ឋាន គ.ជ.អ.ប អំពីការរៀបចំផែនការការងារសម្រាប់ការណែនាំ និងផ្សព្វផ្សាយប្រព័ន្ធព័ត៌មានវិទ្យា និងប្រព័ន្ធទិន្នន័យនានានៅថ្នាក់ក្រុង ស្រុក ខណ្ឌ
- កំណត់ឱ្យបានច្បាស់លាស់អំពីជនបង្គោល ឬបុគ្គលិកកិច្ចសន្យាដែលទទួលបន្ទុកថែរក្សាប្រព័ន្ធព័ត៌មានវិទ្យានៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងអាចទំនាក់ទំនងបានតាមរយៈទូរស័ព្ទ ឬតាមរយៈសារអេឡិចត្រូនិច

- ណែនាំអំពីប្រព័ន្ធព័ត៌មានវិទ្យាថ្មីសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗតាមរយៈការបណ្ដុះបណ្ដាល និងការចុះគាំទ្រ ស្របតាមការណែនាំរបស់ថ្នាក់ជាតិ។

## ៣. ការទទួលខុសត្រូវ និងខ្សែគណនេយ្យភាព

បុគ្គលិកព័ត៌មានវិទ្យាថ្នាក់រាជធានី ខេត្ត នៃផអ៣ទី២ ត្រូវចុះកិច្ចសន្យាបំពេញការងារជាមួយ និងស្ថិតនៅក្រោមការទទួលខុសត្រូវរួមរបស់ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប។

នៅថ្នាក់រាជធានី ខេត្ត បុគ្គលិកព័ត៌មានវិទ្យាថ្នាក់រាជធានី ខេត្តស្ថិតនៅក្រោមការទទួលខុសត្រូវផ្ទាល់ពីអភិបាលខេត្ត តាមរយៈនាយករដ្ឋបាលខេត្ត និងស្ថិតនៅក្រោមការគ្រប់គ្រងទូទៅ និងមានគណនេយ្យភាពចំពោះគណៈកម្មាធិការគ្រប់គ្រងមណ្ឌលពាក់ព័ន្ធនឹងការងារនៅក្នុងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត និងស្ថិតនៅក្រោមការគ្រប់គ្រង និងសម្របសម្រួលរបស់ទីប្រឹក្សាគ្រប់គ្រងកម្មវិធីថ្នាក់រាជធានី ខេត្ត និងបន្តគាំទ្រដល់រដ្ឋបាលរាជធានី ខេត្តលើការងារប្រព័ន្ធទិន្នន័យ និងប្រព័ន្ធព័ត៌មានវិទ្យានានា។ បន្ថែមលើតួនាទីនេះ បុគ្គលិកព័ត៌មានវិទ្យារាជធានី ខេត្តនឹងអភិវឌ្ឍសមត្ថភាពអំពីប្រព័ន្ធទិន្នន័យ និងប្រព័ន្ធព័ត៌មានវិទ្យានានាដល់រដ្ឋបាលថ្នាក់ក្រោមជាតិពិសេសរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

## ៤. ចំណេះដឹង និងបទពិសោធន៍

- មានបរិញ្ញាបត្រ (Bachelor Degree) ពាក់ព័ន្ធ ឬ/និងបូកផ្សំនឹងបទពិសោធន៍ទាក់ទងនឹងព័ត៌មានវិទ្យា។
- មានជំនាញជាក់ស្តែងក្នុងការរៀបចំផែនការ ការធ្វើរបាយការណ៍ និងការគ្រប់គ្រងគម្រោង។
- មានការយល់ដឹងល្អប្រសើរលើការប្រើប្រាស់កម្មវិធីនានាដូចជា Word/Excel/Power point និងកម្មវិធី Software ផ្សេងៗទៀត។
- មានជំនាញជួសជុល (Troubleshooting) និងចំណេះដឹងជាមូលដ្ឋានស្តីអំពីកម្មវិធីទិន្នន័យ ពាក់ព័ន្ធ។
- សមត្ថភាពបង្កើតបណ្តាញទំនាក់ទំនងជាមួយទីភ្នាក់ងារនានាដែលទាក់ទងនឹងបញ្ហាព័ត៌មានវិទ្យា។
- មានសមត្ថភាពធ្វើការជាក្រុមយ៉ាងមានប្រសិទ្ធភាព។
- មានសមត្ថភាពធ្វើការដោយមានការណែនាំតិច មានការផ្តួចផ្តើមគំនិត និងតាមត្រួតពិនិត្យការងារពីដើមដល់ចប់ដោយខ្លួនឯង។
- និយាយ និងសរសេរភាសាខ្មែរដោយស្ទាត់ជំនាញ និងមានចំណេះដឹងក្នុងការប្រើប្រាស់ភាសាអង់គ្លេសបានល្អ។

**បញ្ជាក់ ៖ មុខតំណែងនេះជាប្រភេទកិច្ចសន្យាការងារ ដូច្នេះបេក្ខជនដែលនឹងត្រូវជ្រើសរើសឲ្យបំពេញការងារ ត្រូវតែមិនមែនជាបុគ្គលិករាជការស៊ីវិល។ ក្នុងករណីដែលបេក្ខជនជាបុគ្គលិករាជការស៊ីវិល បេក្ខជននោះត្រូវដាក់ពាក្យសុំស្ថិតនៅក្នុងភាពទំនេរគ្មានប្រាក់បៀវត្សរ៍ ក្នុងរយៈពេលនៃការបំពេញការងារជាមួយកម្មវិធីជាតិ ។**